តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
<u>សាលក្រម</u>
លេខ ០៦ ខ ចុះថ្ងៃទី ០៧
ខែ មីនា ឆ្នាំ ២០០៦
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ៩៥ ចុះថ្ងៃទី ២០
ខែ កុម្ភៈ ឆ្នាំ ២០០៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

<u>**ចៅក្រមជំនុំជំរះ**</u>

លោក [redacted] ប្រធានតុលាការខេត្ត

<u>**តំណាងអយ្យការ**</u>

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

<u>**ក្រឡាបញ្ជីសវនាការ**</u>

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ៩៥ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដែលមានជនជាប់ចោទ :

ឈ្មោះ **ជ ផ** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកន្សែងលើ ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី ៤ថ្មី ទីលំនៅមុនពេលចាប់ខ្លួននៅភូមិកន្សែងលើ ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប របររកស៊ីធ្វើស្រែ ប្រពន្ធឈ្មោះ **ឧ ផ** មានកូន ០៣នាក់ ។ ឪពុកឈ្មោះ **ឈ ផ** (ស) ម្តាយឈ្មោះ **ឆ ស** (រ) ទោសពីមុន *គ្មាន* ។

ឃុំខ្លួនថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ។

ត្រូវចោទពីបទ **កាប់រានដី<u>ព្រៃឈើ</u>ខុសច្បាប់** ប្រព្រឹត្តនៅភូមិជប់ជាំ ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ និង មាត្រា ៩៧ ចំណុច ៦ នៃច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ។

-លោក **ឧ គស** នាយខណ្ឌរដ្ឋបាលព្រៃឈើ ជាតំណាងអោយរដ្ឋបាលព្រៃឈើ បានប្តឹងសុំឱ្យតុលាការរឹបអូសដីជូនរដ្ឋ និង ផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

<u>**ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ**</u>

-ឈ្មោះ **ជ ផ** ជាអ្នកស៊ីឈ្នួលអោយថៅកែម្នាក់មិនស្គាល់ឈ្មោះ តែមានទីលំនៅ

*សាលក្រមនេះបានចូលជាស្ថាពរនៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៦*
*ដោយពុំមានគូភាគីណាមួយចូលមកប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ឡើយ ។*
*សៀមរាប,ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
***ក្រឡាបញ្ជី***
***ហត្ថលេខា និង ត្រា***
[redacted]

ក្នុងខេត្តសៀមរាប មានកម្មករចំនួន ១៥នាក់ តែឈ្មោះ ៨ ៨ មិនបានស្គាល់ឈ្មោះពួកគេទេ កាប់ក្នុងមួយថ្ងៃបាន ឈ្នួល ៥.០០០រុ០០ ( ប្រាំពាន់រៀល) ថៅកែសន្យាឱ្យធ្វើចំការនៅទីនោះទៀតផង ។

នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៦ ឈ្មោះ ៨ ៨ ទៅកាប់ព្រៃរយៈពេល ០៦ថ្ងៃមានទំហំ ០៦ហិកតា ថៅកែក៏បានអោយឈប់សំរាកមួយរយៈសិនឈ្មោះ ៨ ៨ បានបើកប្រាក់រយៈពេល ០៣ថ្ងៃចំនួន ១៥.០០០រុ០០ ( មួយម៉ឺនប្រាំពាន់រៀល) ។

លុះដល់ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ឈ្មោះ ៨ ៨ ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តងនៅភូមិល្អក់ ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ ៨ ៨ បានឆ្លើយថា នៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ មានមនុស្សប្រុសម្នាក់អាយុ ប្រហែលជា ៤០ឆ្នាំមិនស្គាល់ឈ្មោះ និង មិនស្គាល់ទីលំនៅបានមកជួលខ្លួនអោយត្រួសព្រៃឱ្យគេក្នុងមួយហិកតា ១០០.០០០រុ០០ (ដប់ម៉ឺនរៀល) ឬ ក៏គិតក្នុងមួយថ្ងៃ ៥.០០០រុ០០ ( ប្រាំពាន់រៀល) ហើយបានបញ្ជាក់ថា បើ ត្រួសស្អាតគេឱ្យធ្វើចំការនៅទីនោះ ខ្លួនក៏យល់ព្រមជួលក្នុងមួយថ្ងៃប្រាំពាន់រៀលជាមួយនឹងកម្មករឯទៀតចំនួន ១៥ នាក់ ។

នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៦ ខ្លួនបានទៅត្រួសព្រៃបានរយៈពេល ០៦ថ្ងៃ ថៅកែទើបតែបើកប្រាក់ អោយរយៈពេល ០៣ថ្ងៃចំនួន ១៥.០០០រុ០០ ( មួយម៉ឺនប្រាំពាន់រៀល) នៅជំពាក់ប្រាក់ ០៣ថ្ងៃទៀត ដោយបាន ឱ្យខ្លួនឈប់ត្រួសព្រៃសិន ។ ការកាប់ព្រៃនោះនៅកន្លែងចំបក់ស្លែពណិ ក្នុងភូមិជប់ជាំ ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប មានគ្នា ១៥នាក់ មានទំហំប្រហែល ០៦ហិកតា ខ្លួនមិនបានដឹងថា ថៅកែមានដីទំហំប៉ុន្មានទេចំពោះ ការកាប់នោះដីវាលស្រាប់ និង មានកូនឈើតូចៗមិនបានកាប់ឈើធំៗទេ ។

-លោកមេឃុំបានផ្សព្វផ្សាយឱ្យប្រជាជនឈប់កាប់ព្រៃដាំចំការស្រូវ ក្នុងតំបន់ព្រៃសម្បទានទៀតទៅព្រោះ មានសមត្ថកិច្ចគ្រប់គ្រងហើយ ចំពោះខ្លួនជាអ្នកស៊ីឈ្នួលកាប់ព្រៃឱ្យគេទេ មិនបានកាប់យកខ្លួនឯងទេ ដោយសុខ ចិត្តប្រគល់ដីអោយសមត្ថកិច្ចគ្រប់គ្រងតទៅ ។

-លោក **ឧ គស** តំណាងឱ្យរដ្ឋបាលព្រៃឈើបានឆ្លើយថា ដីនេះពីមុនមកជាដីព្រៃធ្វើអាជីវកម្ម តែក្រោយ មករដ្ឋបានប្រគល់ឱ្យមកខាងរដ្ឋបាលព្រៃឈើជាអ្នកគ្រប់គ្រងថែរក្សា មិនអោយមានការកាប់បំផ្លាញទេ ដោយមាន មនុស្សទៅស៊ីឈ្នួលកាប់រានដី ហើយបានប្រាប់ថា ថៅកែនៅទីរួមខេត្តសៀមរាប តែមិនស្គាល់ឈ្មោះពេលនេះខ្លួន សុំឱ្យតុលាការរឹបអូសដីនេះប្រគល់ជូនរដ្ឋវិញ ។

-ឈ្មោះ **រ រ** ជាមេឃុំបានឆ្លើយថា ខ្លួនធ្វើជាមេឃុំចាន់ស តាំងពីឆ្នាំ ១៩៨៧ រហូតមកទល់សព្វថ្ងៃនេះ នៅក្នុងឃុំខ្លួនប្រជាជនភាគច្រើនធ្វើស្រែ និង ដាំចំការ ។ ចំពោះដីស្រែអានការបែងចែកត្រឹមត្រូវ ការដាំចំការមាន ពីររបៀប ចំការដែលកាប់រានដីជ្រះស្រឡះ គេដាំសណ្តែក និង ដាំពោត សណ្តែកដី និង ឪឡឹក ។ ចំពោះចំការមួយ ទៀត គឺប្រជាជនតែងតែទៅត្រួសព្រៃហើយដាំស្រូវនៅឆ្ងាយៗពីផ្ទះនៅក្នុងតំបន់ព្រៃសម្បទានរួចទុកចោលឱ្យព្រៃ ដុះឡើងវិញ ដល់រដូវពួកគេកាប់ព្រៃដាំស្រូវជាថ្មី កាលពីមុនមិនមានសមត្ថកិច្ចចុះហាមឃាត់ទេ ក្រោយមកនៅ ចុងឆ្នាំ ២០០៥ ខាងរដ្ឋបាលព្រៃឈើបានគ្រប់គ្រងបន្តពីអង្គការហ្វាវ បានហាមឃាត់ប្រជាជនមិនឱ្យទៅកាប់ព្រៃ នៅទីនោះទៀតទេ ។

នៅថ្ងៃមិនចាំក្នុងខែ កុម្ភៈ ឆ្នាំ ២០០៦ ខ្លួនបានមកធ្វើសិក្ខាសាលានៅមន្ទីរពេទ្យព្រះបាទជ័យវរ្ម័នទី៧

ជាមួយនិងក្រុមរដ្ឋបាលព្រៃឈើ ថាឈប់ឱ្យកាប់ឈើក្នុងព្រៃសម្បទាន ។ ពេលនេះខ្លួនត្រឡប់ទៅវិញបានប្រាប់ប្រជាជនបន្តគ្នា ហើយប្រជាជនបានឈប់កាប់ហើយ ។ ចំពោះឈ្មោះ ផ ផ បានកាប់រានដីព្រៃសម្បទានមុនខ្លួន មកសិក្ខាសាលាប្រហែលជា ១០ថ្ងៃ ក្រោយពីខ្លួនហាមឃាត់ទៅគេបានឈប់កាប់ហើយ បើតាមលោកមេភូមិគាត់ថាអ្នកដែលកាប់នោះមានគ្នាប្រហែលជាង ១០នាក់ មិនដឹងជាកាប់យកខ្លួនគេឬយ៉ាងណាទេ ។ ខ្លួនសូមបញ្ជាក់ឈ្មោះ ផ ផ ពិតជាបានត្រួសព្រៃយកឈ្នួលឱ្យគេពិតមែន ។

**<u>តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា</u>**

ឆ្លងតាមការសួរដេញដោល និង ចម្លើយសារភាពរបស់ជនជាប់ចោទរួចមកឃើញថា ឈ្មោះ ផ ផ ពិតជាបានទៅត្រួសព្រៃយកឈ្នួលពិតមែន តែក្រោយមកក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន មានពិរុទ្ធភាពធ្ងន់ធ្ងរលើឈ្មោះ ផ ផ ពីបទកាប់រានព្រៃឈើខុសច្បាប់ ប្រព្រឹត្តនៅភូមិជប់ជាំ ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

ហេតុនេះសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ២៥៨ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៦ ទុកជាបានការពេញទាំងមូល ។

សូមតុលាការផ្តន្ទាទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា ៣៣ និង មាត្រា ៩៧ ចំណុច ៦ នៃច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ។

ជនជាប់ចោទឈ្មោះ ផ ផ បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-បានស្តាប់ចំលើយជនជាប់ចោទ
-បានស្តាប់ចម្លើយតំណាងរដ្ឋបាលព្រៃឈើ
-បានស្តាប់ចម្លើយលោកមេឃុំ
-បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
-បានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**<u>តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ</u>**

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-ឈ្មោះ ផ ផ បានទៅស៊ីឈ្នួលត្រួសព្រៃឱ្យចៅកែមិនស្គាល់ឈ្មោះរយៈពេល ០៦ថ្ងៃ ក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ដោយបានបើកប្រាក់ចំនួន ០៣ថ្ងៃរួចឈប់សំរាក តែក្រោយមកសមត្ថកិច្ចបានស្រាវជ្រាវឃាត់ខ្លួនតែម្តង ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ ផ ផ មានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៣ និង មាត្រា ៩៧ ចំណុច ៦ នៃច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលបានកំណត់ទោសពី ០៥ឆ្នាំទៅ ១០ឆ្នាំ ។

-ប៉ុន្តែបើពិនិត្យឱ្យជិតដល់ទៅឃើញថា ជនជាប់ចោទឈ្មោះ ផ ផ ជាមនុស្សខ្វះការពិចារណា ជីវភាពក្រលំបាក ដោយបានទៅស៊ីឈ្នួលកាប់ព្រៃឱ្យគេក្នុងមួយថ្ងៃ ៥.០០០៛០០ ហើយទើបតែប្រព្រឹត្តបទល្មើស

ជាលើកដំបូងបានសារភាពនូវទោសកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ។

-មាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលបាននិយាយពីការព្យួរទោសនោះ តុលាការនឹងពិចារណាដល់បញ្ហានេះ ។

-សាលាកប័ត្រទោសទណ្ឌពិន័យជាប្រាក់សរុប ១២០.០០០.០០០៛០០ ( មួយរយម្ភៃលានរៀល) នោះតុលាការនឹងពិចារណាទៅលើអ្នកដែលជួលកម្មករឱ្យទៅកាប់ព្រៃឈើនេះ ។

-តំណាងរដ្ឋបាលព្រៃឈើបានសុំទាមទារព្រៃឈើ ដែលកាប់បំផ្លាញចំនួន ៦០.០០០ម៉ែត្រការេ នោះយកគ្រប់គ្រងវិញ តុលាការគប្បីពិចារណាដល់បញ្ហានេះ ។

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះ **ផ ផ** ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ( ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន តែទោសនេះត្រូវព្យួរចិរវេលាសាកល្បង ០៥ឆ្នាំ ។

ពីបទ **កាប់រានដីព្រៃឈើ** តាមមាត្រា ៣៣ និង មាត្រា ៩៧ កថាខណ្ឌទី ១ ចំណុច ៦ នៃច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ និង តាមមាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ប្រព្រឹត្តនៅភូមិជប់ជាំ ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

២-ដីមានទំហំ ៦០.០០០ម៉ែត្រការេស្មើ ០៦ហិកតា មានទីតាំងត្រង់ចំណុចព្រៃជាំ ស្ថិតក្នុងភូមិជប់ជាំ ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប ត្រូវរឹបអូសប្រគល់អោយសមត្ថកិច្ចរដ្ឋបាលព្រៃឈើ គ្រប់គ្រងចាប់ពីពេលនេះតទៅ ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា**
[redacted]

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និង ត្រា**
[redacted]